ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា

លេខាធិការដ្ឋានមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព (ម.អ.ស.) សូមជម្រាបជូនដំណឹងដល់សាធារណៈជនឱ្យបានជ្រាបថា លេខាធិការដ្ឋាន ម.អ.ស. ត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា សរុបចំនួន ៦ រូប ដែលនឹងបំពេញមុខតំណែងដូចខាងក្រោម៖

| | |
|---|---|
| ១. បុគ្គលិកផ្នែកវិភាគ និងពិនិត្យហិរញ្ញវត្ថុ | ចំនួន ២ រូប |
| ២. បុគ្គលិកផ្នែកវិភាគ និងវាយតម្លៃហានិភ័យ | ចំនួន ២ រូប |
| ៣. បុគ្គលិកផ្នែកគ្រប់គ្រង និងអភិវឌ្ឍន៍ធុរកិច្ច | ចំនួន ២ រូប |

បេក្ខជន បេក្ខនារីត្រូវមានលក្ខណៈសម្បត្តិ គុណវុឌ្ឍិ និងបំពេញលក្ខខណ្ឌនៃការដាក់ពាក្យដូចខាងក្រោម៖

ក. មានសញ្ជាតិខ្មែរ

ខ. មានសញ្ញាបត្រកម្រិតអនុបណ្ឌិត និងបណ្ឌិតផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ គ្រប់គ្រងធុរកិច្ច ឬ សញ្ញាបត្រផ្នែកពាក់ព័ន្ធ ជាមួយបទពិសោធន៍ការងារចាប់ពី ២ ឆ្នាំ ឡើង ឬ សញ្ញាបត្រកម្រិតបរិញ្ញាបត្រជាមួយបទពិសោធន៍ការងារចាប់ពី ៥ ឆ្នាំ ឡើងទៅតាមមុខតំណែងដែលបានដាក់ពាក្យ

គ. មានចំណេះដឹងភាសាអង់គ្លេសទាំងការស្តាប់ និយាយ និងសរសេរ

ឃ. មានអត្តចរិតសមរម្យ ចេះអត់ធ្មត់ ព្យាយាម ព្រមទាំងមានស្មារតីក្នុងការសិក្សាស្រាវជ្រាវ និងមានទំនួលខុសត្រូវខ្ពស់។

បេក្ខជន បេក្ខនារីដែលមានបំណងចង់ដាក់ពាក្យ អាចផ្ញើឯកសារដាក់ពាក្យស្នើសុំ (រួមមានប្រវត្តិរូបការងារ និងលិខិតបង្ហាញចំណាប់អារម្មណ៍) តាមរយៈសារអេឡិចត្រូនិក (E-mail) ៖ info@edf.gov.kh ចាប់ពីថ្ងៃជូនដំណឹង រហូតដល់ *ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០២៤ វេលាម៉ោង ១៧:០០នាទី ល្ងាច។* បេក្ខជន បេក្ខនារីដែលត្រូវបានជ្រើសរើសចូលដំណាក់កាលសម្ភាសន៍ នឹងត្រូវបានទាក់ទងមកធ្វើការសម្ភាសន៍ផ្ទាល់ បន្ទាប់ពីការបិទទទួលពាក្យស្នើសុំ។/

ថ្ងៃ ពុធ ៣កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០២៤